អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន
# ដីកាបញ្ជូនសំណុំរឿងដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ
# នៅក្នុងសំណុំរឿង ០០៤/២ (អោ អាន)

កាលពីថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបញ្ជូនសំណុំរឿងអនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ដោយបានស្នើសុំឲ្យសហព្រះរាជអាជ្ញាដាក់សេចក្តីសន្និដ្ឋានស្ថាពររបស់ខ្លួននៅក្នុងសំណុំរឿង ០០៤/២។ អនុលោមតាមវិធាន ៦៦(៥)នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញា ក្នុងពេលនេះមានរយៈពេលរហូតដល់ ៣ (បី) ខែដើម្បីដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួន។

ក្រោយរយៈពេលនេះ មេធាវីការពារក្តីនឹងមានរយៈពេលសមស្របនៅក្នុងការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា។ សហចៅក្រមស៊ើបអង្កេត នឹងចេញដីកាដំណោះស្រាយក្នុងពេលមួយសមស្របក្រោយពេលទទួលបានសេចក្តីសន្និដ្ឋានពីភាគីទាំងសងខាង។

*ចំពោះព័ត៌មានបន្ថែមទៀត សូមទាក់ទង៖*

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរសព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh

**លោកស្រី ហាយ៉ាត់ អាប៊ូ-សាឡេស**
មន្ត្រីព័ត៌មានសាធារណៈ
ទូរសព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ៩៣៦
សារអេឡិចត្រូនិក៖ abusaleh@un.org